# ការរក្សាក្មេងៗអាយុក្រោមប្រាំឆ្នាំ ឲ្យមានសុខភាពល្អ បន្ទាប់ពីឆ្លងជំងឺរបេង៖ *អ្វីៗដែលមាតាបិតាត្រូវដឹង*

ជំងឺរបេង (Tuberculosis, TB) ឬហៅសង្ខេបថា របេង ឆ្លងរាលដាលតាមខ្យល់អាកាស។ អ្នកអាចដកដង្ហើមចូលមេរោគ ដែលបណ្តាលឲ្យមានរបេង បើសិនអ្នកចំណាយពេលជាមួយជនណាម្នាក់ ដែលមានជំងឺរបេង។ បើសិនក្មេងអាយុក្រោម 5 ឆ្នាំ ដកដង្ហើមចូលមេរោគរបេង គេអាចនឹងឈឺថ្កាត់ធ្ងន់ធ្ងរណាស់។

ការក្អក ឬការមានគ្រុនក្តៅ ចំនួន **2-3** អាទិត្យ ឬយូរជាង



ការឈឺថ្កាត់ ខ្សោយកំឡាំង ឬអស់កំឡាំង



មិនសូវលេង ខុសពីធម្មតា



មិនញ៉ាំអាហារ ឬបៅដោះមិនល្អ



ការស្រកទំងន់ ឬមិនឡើងទំងន់



**តើខ្ញុំអាចរក្សាកូនរបស់ខ្ញុំ ឲ្យមានសុខភាពល្អដូចម្តេច?**
បើសិនអ្នកបានដឹង ថាកូនរបស់អ្នកបានទាក់ទងជាមួយជនណាម្នាក់ដែលមានរបេង ត្រូវទាក់ទងទៅក្រសួងសុខភាពសាធារណៈ តាមតំបន់របស់អ្នក ដើម្បីជួយកូនរបស់អ្នក ឲ្យបានការថែទាំដែលគេត្រូវការ។ ការធ្វើតេស្ត និងការព្យាបាល អាចជួយរក្សាកូនរបស់អ្នក ឲ្យមានសុខភាពល្អ។

កូនរបស់អ្នក គួរតែជួបអ្នកផ្តល់ការថែទាំសុខភាព ដើម្បីពិនិត្យរូបកាយ ថតអិក្សរេស្មូត និងដោះស្បែកធ្វើតេស្តរបេង ឬយកឈាមធ្វើតេស្តរបេង។ វេជ្ជបណ្ឌិតរបស់អ្នក អាចនឹងឲ្យអនុសាសន៍ប្រើថ្នាំ សូម្បីតែបើការធ្វើតេស្តនៃកូនរបស់អ្នក គឺជាអវិជ្ជមានក៏ដោយ។

**តើហេតុអ្វីត្រូវបានឲ្យអនុសាសន៍ប្រើថ្នាំ បើសិនការធ្វើតេស្តរបេងនៃកូនរបស់ខ្ញុំ គឺជាអវិជ្ជមាន?**
វាអាចប្រើពេលដល់ទៅពីរខែ សំរាប់ការធ្វើតេស្តរបេងក្លាយជាវិជ្ជមាន បន្ទាប់ពីកូនរបស់អ្នកបានឆ្លងមេរោគរបេង។ វាគឺជាសារៈសំខាន់ ដើម្បីឲ្យរូបកាយនៃកូនរបស់អ្នក មានពេលគ្រប់គ្រាន់ ដើម្បីបង្ហាញថាតើគេបានដកដង្ហើមចូល មេរោគរបេងឬអត់។ បើសិនការធ្វើតេស្តរបេងដំបូងរបស់គេ គឺជាអវិជ្ជមាន កូនរបស់អ្នកអាចនឹងត្រូវការធ្វើតេស្តលើកទីពីរ ក្នុងពេលពីរបីអាទិត្យ។

មានថ្នាំពេទ្យ ដើម្បីការពារកូនតូចៗរបស់អ្នក ខណៈគេកំពុងរង់ចាំសំរាប់ការធ្វើតេស្ត លើកទីពីររបស់គេ។ ការព្យាបាលនេះគឺហៅថា Window Preventive Treatment។ កូនក្មេងៗអាយុក្រោម 5 ឆ្នាំ គឺទំនងនឹងឈឺថ្កាត់ដោយសារជំងឺរបេង ធ្ងន់ធ្ងរណាស់ ម្ល៉ោះហើយការការពារដោយរួសរាន់ នៅអំឡុងរយៈពេលបង្អួចនេះ គឺសំខាន់ខ្លាំងណាស់។

**តើកូនរបស់ខ្ញុំនឹងជាយ៉ាងណា ខណៈលេបថ្នាំរបេង Window Preventive Treatment?**
ក្មេងៗភាគច្រើន ទ្រាំទ្រនឹងថ្នាំរបេងបានល្អណាស់។ បើសិនគេមានរោគសញ្ញាអ្វីមួយ ដែលជាកង្វល់ដល់អ្នក សូមប្រាប់វេជ្ជបណ្ឌិតនៃកូនរបស់អ្នក។

**តើនឹងមានអ្វីកើតឡើង បន្ទាប់ពីការធ្វើតេស្តរបេងលើកទីពីរ?**
បន្ទាប់ពីការធ្វើតេស្តលើកទីពីរ វេជ្ជបណ្ឌិតនៃកូនរបស់អ្នក នឹងសំរេចបើសិនគេត្រូវបន្តលេបថ្នាំទៀត។



COMMONWEALTH OF MASSACHUSETTS
DEPARTMENT OF PUBLIC HEALTH